ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
អគ្គនាយកដ្ឋានពន្ធដារ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីប្រកាសព័ត៌មាន

រាជធានីភ្នំពេញ៖ ថ្ងៃទី ០១ ខែកក្កដា ឆ្នាំ២០១៤ ដោយ អគ្គនាយកដ្ឋានពន្ធដារ

## ការប្រកាសតែងតាំងប្រធានសាខាពន្ធដារខេត្តត្បូងឃ្មុំ

នាព្រឹកថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៤ នៅសាលាខេត្តត្បូងឃ្មុំ មានរៀបចំពិធីប្រកាសតែងតាំងប្រធាន និងថ្នាក់ដឹកនាំនៃសាខាពន្ធដារខេត្ត ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ ដោយមានការចូលរួមជាគណៈអធិបតីពីសំណាក់ឯកឧត្តម **ប្រាជ្ញ ចន្ទ** អភិបាលនៃគណៈអភិបាល ខេត្តត្បូងឃ្មុំ ព្រមទាំងឯកឧត្តម-លោកជំទាវ អស់លោក-លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរខេត្ត មន្ទីរ និងអង្គភាពជំនាញជុំវិញខេត្តត្បូងឃ្មុំយ៉ាងច្រើនកុះករ។



ជាកិច្ចចាប់ផ្តើម ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានសម្តែងនូវសេចក្តីសោមនស្សរីករាយជាអនេក និងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ ដោយត្រូវបានឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ប្រគល់ភារកិច្ចដ៏ខ្ពង់ខ្ពស់ឱ្យធ្វើជាតំណាងចូលរួមក្នុងពិធីប្រកាសតែងតាំងប្រធានសាខាពន្ធដារខេត្តត្បូងឃ្មុំនាព្រឹកនេះ។ ក្នុងនាមឯកឧត្តមរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងនាមឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលផ្ទាល់ ឯកឧត្តមបានសម្តែងនូវការអបអរសាទរយ៉ាងក្លៀវក្លា និងប្រសិទ្ធពរសព្ទសាធុការយ៉ាងកក់ក្តៅជូនចំពោះអស់លោក ដែលត្រូវចូលកាន់តំណែងជាប្រធានសាខាពន្ធដារខេត្តត្បូងឃ្មុំ និងបានសម្តែងការកោតសរសើរដ៏ស្មោះជូនចំពោះអស់លោកទាំងអស់ ដែលកន្លងមក បានខិតខំបឹងប្រែងយកអស់កំលាំងកាយចិត្ត និងប្រាជ្ញាស្មារតី ជាមួយនឹងភាពស្វាហាប់ និងការប្តេជ្ញាខ្ពស់ ក្នុងការជួយជ្រោមជ្រែងដឹកនាំសាខាពន្ធដារខេត្តកំពង់ចាមប្រកបដោយប្រសិទ្ធភាព ភាពស័ក្តិសិទ្ធិ និងទទួលបាននូវជោគជ័យគួរជាទីមោទនៈ។









ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលបានជម្រាបជូនអង្គពិធីយ៉ាងដូច្នេះថា ការតែងតាំង ការដំឡើងតួនាទី ឬការសម្រួលភារកិច្ចមន្ត្រីសាខាពន្ធដារខេត្តនាពេលនេះ គឺជាការធ្វើកំណែទម្រង់ស្ថាប័ន និងការផ្លាស់ប្តូរការទទួលខុសត្រូវ និងបទពិសោធការងារ សំដៅធ្វើឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់ ក្នុងការកៀរគរប្រមូលចំណូលថវិកាជាតិស្របទៅតាម **“កម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី២”** ដែលជាជ្រុងមួយនៃអភិបាលកិច្ចល្អ ដែលជាស្នូលនៃ **“យុទ្ធសាស្រ្តចតុកោណ-ដំណាក់កាលទី៣”** របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី**។ ឯកឧត្តមបានគូសបញ្ជាក់ផងដែរថា ចំណូលពន្ធមានការកើនឡើងជាលំដាប់ពីមួយឆ្នាំទៅមួយឆ្នាំ។ ជាក់ស្តែង នៅឆ្នាំ១៩៩៥ ចំណូលពន្ធដារប្រមូលបាន **០,៧% នៃ ផ.ស.ស** និងនៅឆ្នាំ២០០៣ សម្រេចបាន **១,៩% នៃ ផ.ស.ស**។ នៅឆ្នាំ២០១២ អគ្គនាយកដ្ឋានប្រមូលចំណូលពន្ធ-អាករគ្រប់ប្រភេទបានចំនួន ២.៩៦២.១៣៣ លានរៀល (គិតជាដុល្លារស្មើ ៧៤០,៥៣ លានដុល្លារ សហរដ្ឋអាមេរិក) គឺស្មើនឹង **១០០,៦០%** នៃផែនការច្បាប់ ខណៈដែលក្នុងឆ្នាំ២០១៣ ប្រមូលបាន ៣.៦០៤.៨៩២ លានរៀល (គិតជាដុល្លារស្មើ ៩០១,២២ លានដុល្លារ សហរដ្ឋអាមេរិក) គឺស្មើនឹង **១០៤%** នៃផែនការកំណត់ដោយច្បាប់ ឬស្មើនឹង **៥,៨៧% នៃ ផ.ស.ស** ។ សម្រាប់ឆ្នាំ២០១៤ នេះ អគ្គនាយកដ្ឋានពន្ធដារត្រូវប្រមូលចំណូលឱ្យបាន ៣.៩៧៥.១៦០ លានរៀល (គិតជាដុល្លារប្រមាណ ៩៩៣,៨ លានដុល្លារ សហរដ្ឋអាមេរិក)។

បើពិនិត្យលើនិន្នាការលទ្ធផលចំណូលឃើញថា ការប្រមូលចំណូលពន្ធផ្ទៃក្នុងដែលជាដែនសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានពន្ធដារ កាន់តែដើរតួនាទីយ៉ាងសំខាន់សម្រាប់ជាប្រយោជន៍ថវិកាជាតិ ហើយនាអនាគត នឹងរឹងរឹតតែមានសារៈសំខាន់ខ្លាំងឡើងៗថែមទៀត នៅពេលដែលសមាហរណកម្មសេដ្ឋកិច្ចអាស៊ានត្រូវបង្កើតឡើងនៅឆ្នាំ២០១៥។

ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានសង្កត់ធ្ងន់ថា នៅក្នុង “**យុទ្ធសាស្ត្រកៀរគរប្រមូលចំណូលរយៈពេលមធ្យម ឆ្នាំ ២០១៤-២០១៨**” សម្រាប់ឆ្នាំ២០១៤ រាជរដ្ឋាភិបាលមិនមានគោលនយោបាយក្នុងការដំឡើងអត្រាពន្ធទេ លើកលែងតែអាករពិសេសលើទំនិញមួយចំនួនដែលធ្វើឲ្យប៉ះពាល់ដល់សុខភាព និងបរិស្ថាន។ ដូច្នេះ ស្ថិតក្នុងបរិបទនៃការមិនដំឡើងពន្ធនេះ អគ្គនាយកដ្ឋានពន្ធដារ បានដាក់ចេញនូវមធ្យោបាយសំខាន់ៗ និងធំៗចំនួន ៤ សម្រាប់ជំរុញការកៀរគរប្រមូលចំណូលឲ្យបានគ្រប់តាមផែនការ ឬលើសផែនការដែលច្បាប់បានកំណត់ រួមមាន ÷

**<u>ទី១- ការកែលំអរដ្ឋបាលសារពើពន្ធ</u>** តាមរយៈការពង្រឹងការផ្តល់សេវាជូនអ្នកជាប់ពន្ធ ធ្វើទំនើបកម្មប្រព័ន្ធព័ត៌មានវិទ្យា ពង្រឹងការធ្វើសវនកម្មឲ្យមានប្រសិទ្ធភាព ពង្រឹងការប្រមូលចំណូលនៅតាមសាខាពន្ធដារខេត្ត-ខណ្ឌ ឲ្យអស់លទ្ធភាព និងសក្តានុពលភាពដែលមាន។

**<u>ទី២- ការពង្រឹងអភិបាលកិច្ចល្អ</u>** តាមរយៈការពង្រឹងការអនុវត្តក្រមសីលធមិ កែលំអស្ថាប័ន ប្រព័ន្ធគ្រប់គ្រងការងាររបៀបរបបធ្វើការងារ ការផ្លាស់ប្តូរផ្នត់គំនិត (Mindset) របស់មន្ត្រីពន្ធដារ ធ្វើយ៉ាងណាត្រូវមានអាកប្បកិរិយាថ្លៃថ្នូរ មានសីលធមិល្អ មានភាពម៉ឺងម៉ាត់ខាងទិដ្ឋភាពច្បាប់ បម្រើសេវាជូនអ្នកជាប់ពន្ធប្រកបដោយ
វិជ្ជាជីវៈខ្ពស់ និងប្រមូលចំណូលពន្ធប្រកបដោយតម្លាភាព និងប្រសិទ្ធភាព។

**<u>ទី៣- ការកែទម្រង់ច្បាប់ និងបទប្បញ្ញត្តិផ្សេងៗ</u>** តាមរយៈការពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិស្តីពីពន្ធដារ ការរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីពន្ធដារ រៀបចំកែលម្អលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ។

**<u>ទី៤- ការពង្រឹងវប្បធម៌បង់ពន្ធ</u>** គឺត្រូវណែនាំឲ្យអ្នកជាប់ពន្ធមានទម្លាប់បង់ពន្ធ ហើយត្រូវមានភាពគត់មត់ក្នុងការងារចំពោះអ្នកជាប់ពន្ធ ពោលគឺធ្វើយ៉ាងណាឲ្យអ្នកជាប់ពន្ធមកបង់ពន្ធឲ្យបានគ្រប់ៗគ្នា ដោយប្រើវិធីសាស្ត្រត្រជាក់ និងក្តៅតាមដែលអាចធ្វើទៅបាន ស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន និងធ្វើយ៉ាងណាឲ្យពួកគាត់ចូលរួមបំពេញកាតព្វកិច្ចសារពើពន្ធដោយស្ម័គ្រចិត្ត និងដោយសប្បាយចិត្ត។

ក្នុងឱកាសប្រសើរថ្លៃថ្លានេះ ក្នុងនាមឯកឧត្តម **អូន ព័ន្ធមុនីរ័ត្ន** រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្នុងនាមឯកឧត្តមប្រតិភូផ្ទាល់ ឯកឧត្តមបានផ្តាំផ្ញើជូនអស់លោកប្រធានសាខាពន្ធដារខេត្តត្បូងឃ្មុំ ដែលទើបត្រូវបានតែងតាំងថ្មី នូវអនុសាសន៍ ដូចតទៅ÷

១- តាមការណែនាំដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តមរដ្ឋមន្ត្រី មន្ត្រីពន្ធដារគ្រប់លំដាប់ថ្នាក់ត្រូវខិតខំអនុវត្តឲ្យបានខ្ជាប់ខ្ជួននូវបទបញ្ជា និងវិធានការទាំង ៤ចំណុច របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលបានដាក់ចេញនៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ នៃរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣ ដែលរួមមាន (ទី១) ត្រូវត្រួតពិនិត្យមើលខ្លួនឯងតាមការចេះឆ្លុះកញ្ចក់ជាប្រចាំ (ទី២) ត្រូវងូតទឹកលាងខ្លួនជាប្រចាំ (ទី៣) ត្រូវចេះដុសក្អែលសំអាតខ្លួនឯង និង(ទី៤) បើមិនដូច្នេះទេ ខ្លួននឹងក្លាយជាកម្មវត្ថុនៃវិធានការដាក់ថ្នាំ ឬរហូតដល់វះកាត់ផង។ ដូច្នេះសូមលោកប្រធានសាខា និងមន្ត្រីគ្រប់លំដាប់ថ្នាក់នៃសាខាពន្ធដារខេត្ត ត្រូវយកចិត្តទុកដាក់ខ្ពស់ចំពោះបទបញ្ជា និងវិធានការទាំង ៤ ចំណុច ខាងលើនេះ សម្រាប់ការអនុវត្តការងារតាមសមត្ថកិច្ចនីមួយៗ។

២-ត្រូវរៀបចំកិច្ចប្រជុំប្រចាំខែ ដើម្បីបូកសរុបលទ្ធផលការងារដែលបានអនុវត្តកន្លងមក និងលើកទិសដៅសម្រាប់ការអនុវត្តបន្ត។ នៅក្នុងកិច្ចប្រជុំទៀតសោត ត្រូវអនុញ្ញាតឲ្យមន្ត្រីក្រោមឱវាទ មានឱកាសលើកឡើងនូវចំណុចវិជ្ជមាន និងអវិជ្ជមាន និងចំណុចសកម្មនិងអសកម្ម ព្រមទាំងបញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងសាខារបស់ខ្លួន ដើម្បីរិះរកវិធីសាស្ត្រក្នុងការកែលំអ និងធ្វើឲ្យការគ្រប់គ្រងការប្រមូលចំណូលកាន់តែមានប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ។

៣-ត្រូវរៀបចំផែនការសកម្មភាព និងកម្មវិធីការងាររបស់សាខាឲ្យបានច្បាស់លាស់ ដើម្បីងាយស្រួលចាត់ចែងដាក់ឲ្យមន្ត្រីក្រោមឱវាទអនុវត្តប្រកបដោយតម្លាភាព ស៊ីសង្វាក់និងប្រទាក់ក្រឡាគ្នា សំដៅធានាបាននូវប្រសិទ្ធភាពខ្ពស់ក្នុងការប្រមូលចំណូល។

៤-ត្រូវមានសិល្បៈក្នុងការគ្រប់គ្រង និងដឹកនាំការងារ ដោយត្រូវចេះបែងចែកភារកិច្ចឲ្យបានសមស្រម និងប្រកបដោយសមធម៌ និងលើកទឹកចិត្តមន្ត្រីដែលមានសមត្ថភាពការងារ សំដៅធ្វើឲ្យមានកិច្ចសហការល្អ សាមគ្គីភាពផ្ទៃក្នុង ដែលជាកត្តាគន្លឹះនៃភាពជោគជ័យរបស់សាខា។

៥-ត្រូវខិតខំពង្រឹង និងបង្កើនប្រសិទ្ធភាព និងគណនេយ្យភាពនៃការប្រមូលចំណូល និងការកែលម្អអភិបាលកិច្ចសេវាសាធារណៈ សំដៅធានាបាននូវការអនុវត្តកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ និង "**យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣**" របស់**សម្តេចតេជោ នាយករដ្ឋមន្ត្រី** ឲ្យសម្រេចបានជោគជ័យ ស្របតាមការណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចតេជោនាយករដ្ឋមន្ត្រី** ក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ នៃរាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា នាថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១៣។

៦- ត្រួតពិនិត្យការអនុវត្ត ជំរុញ និងកែលម្អការប្រមូលចំណូលពន្ធលើអចលនទ្រព្យ ដើម្បីបង្កើនប្រសិទ្ធភាពសេវា និងការប្រមូលពន្ធអចលនទ្រព្យ ។ ជំរុញការផ្សព្វផ្សាយដល់ម្ចាស់អចលនទ្រព្យដែលមិនទាន់មកបង់ពន្ធ ឲ្យមកបង់ពន្ធឲ្យបានគ្រប់គ្នា។

៧- ពង្រឹង និងកែលម្អរដ្ឋបាលសាខាពន្ធដារខេត្ត ពង្រឹងកិច្ចការសវនកម្មពន្ធ ពិនិត្យលទ្ធភាពនៃការពង្រីក មូលដ្ឋានយកពន្ធ បង្កើនប្រសិទ្ធភាពនៃការប្រមូលពន្ធ និងការធ្វើវិចារណកម្មប្រព័ន្ធលើកទឹកចិត្ត។

៨- ពង្រឹងការអនុវត្តកម្មវិធីកែលម្អរចនាសម្ព័ន្ធ ជាពិសេស ការពង្រឹងការអនុវត្តតួនាទី ភារកិច្ច និង ប្រតិបត្តិការរបស់សាខាពន្ធដារ ស្របតាមប្រកាសស្តីពីការរៀបចំ និងប្រព្រឹត្តទៅនៃសាខាពន្ធដារខេត្ត-ខណ្ឌ។

៩- ជំរុញការអនុវត្តផែនការយុទ្ធសាស្ត្របច្ចេកវិទ្យាព័ត៌មាន ជាពិសេស ខាងផ្នែកប្រមូលពន្ធ ដូចជាការ ផ្តល់សេវាជូនអ្នកបង់ពន្ធ ការធ្វើសវនកម្ម និងការត្រួតពិនិត្យប្រទាក់ក្រឡាគ្នា។

១០- ពង្រឹងការអនុវត្តឲ្យបានគ្រប់ជ្រុងជ្រោយ និងឲ្យបានម៉ឺងម៉ាត់នូវរាល់បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ស្តីពីសារពើពន្ធ និងវិសោធនកម្មទាំងឡាយនៃច្បាប់នេះ។

១១-ពង្រឹងការគ្រប់គ្រងប្រមូលពន្ធលើប្រាក់បៀវត្សរបស់បុគ្គលិកអង្គការមិនមែនរដ្ឋាភិបាល ជាពិសេស តាមដានពន្ធលើអត្ថប្រយោជន៍បន្ថែមរបស់ក្រុមហ៊ុន និងអង្គការនានា។

១២- ជំរុញអនុវត្តគោលនយោបាយពង្រីកមូលដ្ឋានយកពន្ធ តាមរយៈការពង្រីក និងពង្រឹងអនុវត្តរបបរបស់ស្វ័យប្រកាស (របបពិត) និងពង្រឹងសវនកម្មលើអ្នកបង់ពន្ធតាមរបបម៉ៅការ។ ជាមួយនេះ សាខាពន្ធដារ ត្រូវរៀបចំធ្វើស្ថិតិអ្នកជាប់ពន្ធឲ្យបានច្បាស់លាស់ ជាពិសេស អ្នកជាប់ពន្ធតាមរបបម៉ៅការ ដើម្បីពិនិត្យផលរបរប្រចាំឆ្នាំដល់កម្រិតត្រូវជាប់ពន្ធតាមរបបស្វ័យប្រកាស សម្រាប់បញ្ចូលទៅជាអ្នកជាប់ពន្ធតាមរបបស្វ័យប្រកាស។

១៣-ជំរុញការរៀបចំបញ្ជីស្ថិតិក្រុមហ៊ុន ដែលមិនព្រមចូលខ្លួនមកទូទាត់បំណុលពន្ធឱ្យបានច្បាស់លាស់ ដើម្បីស្នើសុំទៅអគ្គនាយកដ្ឋានពន្ធដារ មានវិធានការតឹងទារបំណុល។

១៤-បង្កើតឱ្យមានប្រអប់សំបុត្រទទួលពាក្យបណ្ដឹង និងបិទផ្សាយការមិនយកកម្រៃសេវាសាធារណៈ នៅកន្លែងបំពេញការងារ។

១៥-ពង្រឹងកិច្ចសហការជាមួយស្ថាប័នពាក់ព័ន្ធ ដើម្បីធ្វើការផ្ទៀងផ្ទាត់ (Cross Check) នូវព័ត៌មានរបស់អ្នកជាប់ពន្ធ ដើម្បីធ្វើការកំណត់ពន្ធឱ្យមានតម្លាភាព និងភាពត្រឹមត្រូវ។

១៦- ជំរុញការបណ្ដុះបណ្ដាល និងបង្កើនសមត្ថភាពវិជ្ជាជីវៈ និងសីលធម៌របស់មន្ត្រីពន្ធដារ ដើម្បីពង្រឹង សមត្ថភាពស្ថាប័ន និងរដ្ឋបាលសាខាពន្ធដារខេត្តឱ្យបានរឹងមាំ ក្នុងគោលដៅគ្រប់គ្រងឱ្យបានល្អនូវអ្នកបង់ពន្ធតាមរបបស្វ័យប្រកាស និងរបបម៉ៅការ ព្រមទាំងសហការឱ្យបានល្អជាមួយអាជ្ញាធរពាក់ព័ន្ធ ដូចជាស្ថាប័នគយ ជាដើម ដើម្បីទទួលបានព័ត៌មានបន្ថែម សម្រាប់ជាមូលដ្ឋានក្នុងការប្រមូលចំណូលពន្ធជូនរដ្ឋ។

ជាមួយនេះ ឯកឧត្តមបានស្នើអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ ស្ថាប័ន និងអង្គភាពពាក់ពន្ធ័ទាំងអស់ មេត្តាផ្ដល់ការគាំទ្រ និងកិច្ចសហការល្អ ឱ្យកាន់តែរឹងមាំ និងខ្ជាប់ខ្ជួន ដល់សាខាពន្ធដារខេត្តត្បូងឃ្មុំ ក៏ដូចជានាយកដ្ឋានពាក់ព័ន្ធនៃអគ្គនាយកដ្ឋានពន្ធដារ ដើម្បីធានាបានការប្រមូលពន្ធប្រកបដោយប្រសិទ្ធភាពខ្ពស់ សម្រាប់ជាប្រយោជន៍ដល់ថវិកាជាតិ និងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលក៏បានជម្រាបជូនអង្គពិធីផងដែរថា ស្ថាប័នពន្ធដារប្រៀបបានទៅនឹងសរសៃឈាមសម្រាប់ចិញ្ចឹមសរីរាង្គកាយរបស់មនុស្សយ៉ាងដូច្នោះដែរ ប្រសិនបើរាង្គកាយខ្សត់ខ្សោយឈាម ឬគ្មានឈាមទេ នោះសារពាង្គកាយរបស់យើងនឹងមិនអាចរីកលូតលាស់បានទេ ឬត្រូវស្លាប់តែម្ដង។ នេះគឺមានន័យថា បើយើងមិនមានចំណូលឬថវិកាគ្រប់គ្រាន់ យើងក៏មិនអាចអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់ប្រទេសឱ្យមានការរីកចម្រើនបានដែរ។ ដូច្នេះ ពន្ធដារដើរតួនាទីជាស្នូល និងជាគន្លឹះយ៉ាងសំខាន់ ក្នុងការទ្រទ្រង់ដល់កិច្ចអភិវឌ្ឍន៍ប្រទេស។

ឯកឧត្តមមានជំនឿចិត្តយ៉ាងមុតមាំថា ក្រោយពិធីប្រកាសតែងតាំងជាផ្លូវការនេះរួចហើយ ប្រធានសាខាពន្ធដារខេត្តនឹងគ្រប់គ្រង ដឹកនាំការងារប្រមូលចំណូលពន្ធនៃសាខាពន្ធដារខេត្តត្បូងឃ្មុំ ឱ្យមានសន្ទុះរីកចម្រើនខ្លាំងក្លាថែមទៀត ស្របតាមកម្មវិធីកំណែទម្រង់គ្រប់គ្រងហិរញ្ញសាធារណៈ ដំណាក់កាលទី២។

ក្នុងដំណាក់កាលតទៅមុខ ខ្ញុំរឹតតែមានក្ដីសង្ឃឹមជឿជាក់និងទំនុកចិត្តលើការយកចិត្តទុកដាក់ខ្ពស់ របស់ថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់លំដាប់ថ្នាក់ទាំងអស់នៃសាខាពន្ធដារខេត្តត្បូងឃ្មុំ នឹងខិតខំប្រឹងប្រែងយកអស់លទ្ធភាព សហការគ្នាល្អ ដើម្បីជំរុញការកៀរគរប្រមូលចំណូលឱ្យទទួលបានជោគជ័យថែមទៀត តាមការកំណត់ទិសរបស់អគ្គនាយកដ្ឋានពន្ធដារ ក៏ដូចជាក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ជាទីបញ្ចប់ ឯកឧត្តមបានប្រសិទ្ធពរជ័យជូនឯកឧត្តម **ឈ្នាង ចន្ធ** អភិបាលនៃគណៈអភិបាលខេត្តត្បូងឃ្មុំ ជូនអស់លោកប្រធានសាខាពន្ធដារខេត្តដែលទើបត្រូវតែងតាំងថ្មី ព្រមទាំងឯកឧត្តម-លោកជំទាវ អស់លោក-លោកស្រី ជាថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៃអាជ្ញាធរខេត្ត មន្ទីរ-អង្គភាពជំនាញជុំវិញសាលាខេត្ត សូមអស់លោកបានប្រកបដោយសិរីមង្គល វិបុលសុខ សុភមង្គលជានិច្ចនិរន្តរ៍ និងសម្រេចបានជោគជ័យដ៏ត្រចះត្រចង់ក្នុងបេសកកម្មប្រមូលចំណូលចូលថវិកាជាតិ។

**អគ្គនាយកដ្ឋានពន្ធដារ**